# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៤ សសរ

## សេចក្តីសម្រេច

ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីទ្រទ្រង់ការរៀបចំព្រឹត្តិការណ៍ ការប្រកួតកីឡាវាយកូនគោលមិត្តភាពរវាងអង្គទូតនៃប្រទេស អាស៊ាន+៣+ឥណ្ឌា+អូស្ត្រាលី ពីថ្ងៃទី ១៤-១៦ ខែវិច្ឆិកា និង ការប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodian Open 2009 ពីថ្ងៃទី១៦-២២ ខែ វិច្ឆិកា ឆ្នាំ២០០៩ នៅខេត្តសៀមរាប

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- យោងតាមសំណើសុំរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីរៀបចំព្រឹត្តិការណ៍ **"ការប្រកួតកីឡាវាយកូនគោលមិត្តភាពរវាងអង្គទូតនៃប្រទេស អាស៊ាន+៣+ឥណ្ឌា+អូស្ត្រាលី"** ពីថ្ងៃទី១៤-១៦ ខែវិច្ឆិកា និង **"ការប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodian Open 2009"** ពីថ្ងៃទី១៦ ដល់ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០០៩ នៅខេត្តសៀមរាប រួមមានសមាសភាព ដូចតទៅ:

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម | អ៊ឹក ប្រាជ្ញា | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៣- ឯកឧត្តម | សូ ម៉ារ៉ា | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |

www.pheakdeylaw.com

៤- ឯកឧត្តម ស៊ូ គឹរិន្ទ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប អនុប្រធាន

៥- ឯកឧត្តម ហោ សារុន អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិកអចិន្ត្រៃយ៍

៦- ឯកឧត្តម ង៉ាត់ សុខុម អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

៧- ឯកឧត្តម មាស សារិន អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា និងជា
អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សមាជិក

៨- ឯកឧត្តម គីម គុណវឌ្ឍន៍ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ
អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា សមាជិក

៩- ឯកឧត្តម ឆិត ចន្ថា អគ្គនាយកទេសចរណ៍ សមាជិក

១០- ឯកឧត្តម ជា ម៉ូរ៉ា អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ សមាជិក

១១- ឯកឧត្តមឧត្តមសេនីយ៍ឯក ឥត សារ៉ាត់ អគ្គលេខាធិការសហព័ន្ធកីឡាវាយកូនគោលកម្ពុជា សមាជិក

១២- ឯកឧត្តម ម៉ី ម៉ារ៉ាឌី អគ្គនាយករងអាជ្ញាធរអប្សរា សមាជិក

១៣- ឯកឧត្តមឧត្តមសេនីយ៍ទោ ខៀវ សេន អគ្គនាយករងនៃអគ្គនាយកដ្ឋាននយោបាយ
និងកិច្ចការបរទេសនៃក្រសួងការពារជាតិ សមាជិក

១៤- ឯកឧត្តម ឡាយ ឫទ្ធី អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក

១៥- លោក គង់ សូលីដា អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍
និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី សមាជិក

១៦- លោក ផ្លុង ភឿន អគ្គនាយករងទេសចរណ៍ សមាជិក

១៧- ឧត្តមសេនីយ៍ទោ ថោង លឹម ប្រធាននាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ សមាជិក

១៨- ឧត្តមសេនីយ៍ទោ ញាណ ទិម្មុល ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ក្រសួងមហាផ្ទៃ សមាជិក

១៩- លោក ជុំ សុខុម ប្រធាននាយកដ្ឋានអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២០- លោក សូ វិសុទ្ធី ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ ក្រសួងទេសចរណ៍ សមាជិក

២១- លោក សុខ គុងហាប់ ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ សមាជិក

២២- លោក ទ៉ាត់ ចំរើន, អនុប្រធាននាយកដ្ឋានមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា ក្រសួងអប់រំយុវជន និងកីឡា
និងជាទីប្រឹក្សាផ្ទាល់ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សមាជិក

២៣- លោក ណេប សាមុត ជំនួយការឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ សមាជិក

**ប្រការ២:** ក្រុមការងារទ្រទ្រង់ដល់ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនគោលមិត្តភាពរវាងអង្គទូតនៃប្រទេសអាស៊ាន + ៣ +ឥណ្ឌា +អូស្ត្រាលី និងការប្រកួតកីឡាវាយកូនគោលអាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodian Open 2009 មានមុខងារ និងភារកិច្ចដូចតទៅ :

- រៀបចំបដិសណ្ឋារកិច្ចស្វាគមន៍ដល់គណៈប្រតិភូ និងជួយសម្រួលបែបបទនៃការធ្វើដំណើរ និងបែបបទគយជូនដល់គណៈប្រតិភូ និងក្រុមកីឡាករអន្តរជាតិវាយកូនគោលនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ខេត្តសៀមរាប និងច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារផ្សេងៗទៀតទាំងពេលមកដល់ និងត្រឡប់វិញ
- រៀបចំដំណើរទេសនកិច្ចនៅតាមបណ្តាប្រាសាទនានាជូនដល់គណៈប្រតិភូ ក្រុមកីឡាករមុន និងក្រោយការប្រកួត
- រៀបចំពិធីជប់លៀងស្វាគមន៍ និងពិធីជប់លៀងជូនដំណើរនៅតាមប្រាសាទ

- ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អនៅក្នុងពេលប្រកួតកីឡា ជាពិសេសនៅលើទឹកដីខេត្តសៀមរាប
- ធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាក្នុង និងក្រៅប្រទេស
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន ព្រមទាំងមានសិទ្ធិស្វែងរក និងទទួលជំនួយ និងការឧបត្ថម្ភនានាដល់កិច្ចដំណើរការសកម្មភាពនេះ
- ជ្រើសរើសអ្នកជំនាញវាយកូនគោល (Professional Golfer) កម្ពុជាដើម្បីចូលរួម
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការរៀបចំ និងកិច្ចដំណើរការនៃពិធីនេះជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣:** ក្រុមការងារនេះមានលេខាធិការដ្ឋានមួយជាជំនួយការដែលមានទីតាំងនៅទីស្តីការក្រសួងទេសចរណ៍មានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- | លោក **គង់ សូលីដា** | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងទេសចរណ៍ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- | លោក **អ៊ុំ ឃីម** | អគ្គនាយករងទេសចរណ៍ | អនុប្រធាន |
| ៤- | លោក **សូ វិសុទ្ធី** | ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ ក្រសួងទេសចរណ៍ | សមាជិកអចិន្ត្រៃយ៍ |
| ៥- | លោក **សុង តុងហាប់** | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ | សមាជិក |
| ៦- | លោក **ថុក សុខុម** | ប្រធាននាយកដ្ឋានអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងទេសចរណ៍ | សមាជិក |
| ៧- | លោក **ខៃ្វ អាទិត្យា** | អនុប្រធាននាយកដ្ឋាននៃក្រសួងព័ត៌មាន | សមាជិក |
| ៨- | លោក **និន សុទ្ធីវង្ស** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួងទេសចរណ៍ | សមាជិក |
| ៩- | លោក **វ៉ាត់ ចំរើន** | អនុប្រធាននាយកដ្ឋានមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា ក្រសួងអប់រំយុវជន និងកីឡា និងជាទីប្រឹក្សាផ្ទាល់ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | សមាជិក |
| ១០- | លោក **ម៉ៅ សុជាត** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍ | សមាជិក |
| ១១- | ឧត្តមសេនីយ៍ត្រី **ពិន ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១២- | ឧត្តមសេនីយ៍ត្រី **ស៊ិត ណាឌី** | ស្នងការនគរបាលខេត្តសៀមរាប | សមាជិក |
| ១៣- | ឧត្តមសេនីយ៍ត្រី **ម៉ន សាម៉ុន** | មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប | សមាជិក |
| ១៤- | លោកវរសេនីយ៍ទោ **សំ ស៊ីយ៉ាន** | ប្រធានអង្គភាពនគរបាលទេសចរណ៍ខេត្តសៀមរាប | សមាជិក |
| ១៥- | លោក **ជង់ ឡឹម** | ប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ | សមាជិក |
| ១៦- | លោក **ង៉ូវ សេងកាក់** | ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប | សមាជិក |
| ១៧- | លោក **ស្វាយ ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍទេសចរណ៍អង្គរនៃអាជ្ញាធរអប្សរា | សមាជិក |
| ១៨- | លោក **សុង ម៉ាល័យ** | អនុប្រធានការិយាល័យរដ្ឋបាល បុគ្គលិក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |

**ប្រការ៤:** - ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍ក្នុងការបំពេញការងារ ។

- ក្រុមការងារមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទក្នុងករណីមានការចាំបាច់ ។
- សមាជិកនៃក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

www.pheakdeylaw.com

**ប្រការ៥:** ក្រុមការងារនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច។

**ប្រការ៦:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តសៀមរាប ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៣ខាងលើ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *-ក្រសួងព្រះបរមរាជវាំង*
- *-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *-អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *-ដូចប្រការ៧*
- *-ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com